ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ..........✓..........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ពាក់ព័ន្ធការចុះផ្សាយលើគេហទំព័រសារព័ត៌មានវិទ្យុអន្តរជាតិបារាំង (RFI) ស្តីពី "ពលរដ្ឋនៅភូមិស្រែគរថា មិនទាន់ឃើញអាជ្ញាធរមកសួរសុខទុក្ខក្រោយលិចមូលដ្ឋាន"

ពាក់ព័ន្ធនឹងការចុះផ្សាយលើគេហទំព័រសារព័ត៌មានវិទ្យុអន្តរជាតិបារាំង (RFI) កាលពីថ្ងៃ០៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពី "ពលរដ្ឋនៅភូមិស្រែគរថា មិនទាន់ឃើញអាជ្ញាធរមកសួរសុខទុក្ខក្រោយលិចមូលដ្ឋាន" **ក្រសួងរ៉ែ និងថាមពល** សូមធ្វើការបំភ្លឺជូនសាធារណជន ជាពិសេសអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ មានចំនួនសរុប ៨៦០ គ្រួសារ/ខ្នងផ្ទះ ក្នុងនោះមានប្រជាពលរដ្ឋយល់ព្រមទទួលយកគោលនយោបាយសំណង ចំនួន ៧៦២គ្រួសារ ស្មើនិង ៨៨.៦% និងប្រជាពលរដ្ឋពុំទាន់យល់ព្រមទទួលយកគោលនយោបាយសំណង ចំនួន ៩៨គ្រួសារ/ខ្នងផ្ទះ ស្មើនិង ១១.៤% (ភូមិស្រែគរ១-ស្រែគរ២ ចំនួន ៦៨គ្រួសារ/ខ្នងផ្ទះ និងភូមិក្បាលរមាស ៣០គ្រួសារ/ខ្នងផ្ទះ) គិតត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៧។ ទីតាំងថ្មីដែលបានរៀបចំជូនប្រជាពលរដ្ឋរងផលប៉ះពាល់មានហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈសព្វគ្រប់ប្រសើរជាងនៅទីតាំងចាស់ ហើយគ្រួសារនីមួយៗទទួលបានផ្ទះទំហំ ៨០ម៉ែត្រការ៉េ លើដីសម្រាប់សង់ផ្ទះ ១០០០ម៉ែត្រការ៉េ ដីបង្កបង្កើនផល ៥ហិកតា និងអត្ថប្រយោជន៍ផ្សេងៗទៀត។ ចំពោះប្រជាពលរដ្ឋពុំទាន់យល់ព្រមទទួលយកគោលនយោបាយសំណង ក្រុមហ៊ុនក៏បានសាងសង់ផ្ទះ និងបានត្រៀមដីកសិកម្មជូនពួកគាត់នៅភូមិថ្មី រួចរាល់ហើយ។ បច្ចុប្បន្នប្រជាពលរដ្ឋទាំងនោះ បានចាកចេញទៅរស់នៅជាបណ្តោះអាសន្នលើទីទួលដែលពួកគាត់គិតថាជាទីទួលសុវត្ថិភាព ដោយសារនៅលើទីទួលនោះ ពួកគាត់បានចាប់ដីកសិកម្មកំពុងអាស្រ័យផលស្រាប់ និងសង់ផ្ទះសម្រាប់រស់នៅខ្លះរួចហើយ។ ទោះជាយ៉ាងនេះក្តី ក៏អាជ្ញាធរខេត្តពុំយល់ទាស់និងពុំបានចាត់វិធានការតាមផ្លូវច្បាប់រាំងសកម្មភាពនៃការចាប់យកដីខុសច្បាប់នោះដែរ ដោយហេតុថាអាជ្ញាធរខេត្តមិនចង់ឱ្យប្រជាពលរដ្ឋទាំងនោះជួបការលំបាកម្តងហើយម្តងទៀត។

ដូច្នេះក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្រសួងរ៉ែនិងថាមពលសូមធ្វើការបដិសេធចំពោះអត្ថបទព័ត៌មានដែលបានលើកឡើងថា **"មិនទាន់ឃើញអាជ្ញាធរមកសួរសុខទុក្ខ ក្រោយពេលលិចភូមិដ្ឋាន"** នោះ ព្រោះក្រសួងរ៉ែនិងថាមពលបានចាត់តំណាងក្រសួងចំនួន ០២រូប ចុះសហការជាមួយអាជ្ញាធរខេត្តស្ទឹងត្រែង ដើម្បីពិនិត្យ និងតាមដានការដោះស្រាយគោលនយោបាយសំណងនេះជាប្រចាំ។ ជាមួយគ្នានេះដែរ អាជ្ញាធរខេត្តស្ទឹងត្រែងបានបង្កើតក្រុមការងារចម្រុះចុះប្រចាំការតាមគោលដៅសំខាន់ៗក្នុងមូលដ្ឋាន ជាពិសេសក្នុងឃុំ

ស្រែគរ(ចាស់) និងភូមិក្បាលរមាស(ចាស់) ដែលមានប្រជាពលរដ្ឋពុំទាន់យល់ព្រមទទួលយកគោលនយោបាយសំណង ក្នុងគោលបំណងត្រៀមជួយដឹកជញ្ជូនប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋចេញពីតំបន់លិចទឹកទៅកាន់ទីទួលដែលពួកគាត់ចង់ទៅ។ បច្ចុប្បន្ន ទីតាំងដែលប្រជាពលរដ្ឋទៅរស់នៅនោះ ពួកគាត់បានដាក់បំរាមនិងគំរាមថា **«បើចូលកាប់ ចាប់បានដុតចោល»**។ ទោះជាយ៉ាងណាក៏ដោយ ក៏អាជ្ញាធរខេត្ត និងតំណាងក្រសួងរ៉ែនិងថាមពលនៅតែបន្តចុះផ្សព្វផ្សាយអំពីគោលនយោបាយដោះស្រាយសំណងជូនពួកគាត់ឲ្យបានយល់ និងឈប់មានការយល់ច្រឡំលើចំណាត់ការរបស់រាជរដ្ឋាភិបាល។

ជាការពិតណាស់ បន្ទាប់ពីចាកចេញពីភូមិចាស់របស់ពួកគាត់ មករស់នៅបណ្តោះអាសន្ននៅទីទួលនេះ ប្រជាពលរដ្ឋប្រមាណជាង ៧០គ្រួសារ នៃឃុំស្រែគរបាននិងកំពុងប្រឈមនឹងការលំបាក ដូចជា កូនៗមិនបានទៅរៀនសូត្រ ការប្រើប្រាស់ទឹកគ្មានអនាម័យ គ្មានបង្គន់ និងមានបញ្ហាប្រឈមពេលឈឺថ្កាត់យប់ព្រលប់។ ហេតុដូច្នេះ ក្រសួងរ៉ែនិងថាមពល បានទទូចស្នើសុំប្រជាពលរដ្ឋដែលកំពុងជួបការលំបាកទាំងនោះឆាប់យល់ព្រមទៅរស់នៅទីតាំងថ្មីស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះ**ទីតាំងថ្មីនោះមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់ពួកគាត់អាចរស់នៅ និងប្រកបរបរចិញ្ចឹមជីវិតបានប្រសើរ** ក្នុងនោះរួមមានផ្ទះ ដីកសិកម្ម និងមានហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតៗ ដូចជា ផ្លូវ សាលារៀន មណ្ឌលសុខភាព ប៉ុស្តិ៍នគរបាល អណ្តូងទឹក ស្រះទឹក វត្តអារាម ដីសហគមន៍ ដីអារក្សអ្នកតា ដីបញ្ចុះសព ព្រៃសហគមន៍ បណ្តាញអគ្គិសនីតចូលដល់លំនៅដ្ឋានថ្មីរបស់ពួកគាត់ និងអត្ថប្រយោជន៍ផ្សេងៗទៀត។

ទន្ទឹមនេះ ក្រសួងរ៉ែនិងថាមពលសូមជម្រាបជូនថា ការបិទទ្វារទឹកនៃគម្រោងវារីអគ្គិសនីសេសានក្រោម២នឹងមិនមានការបើកទ្វារទឹកវិញនោះទេ ព្រោះការបិទទ្វារទឹកនេះគឺដើម្បីរក្សាទឹកផលិតថាមពលអគ្គិសនី ហេតុនេះកំពស់ទឹកនឹងនៅរេរ ហើយភូមិខាងលើនឹងបន្តលិចរហូត។ ដូចនេះ ក្រសួងរ៉ែនិងថាមពល សូមស្នើសុំកិច្ចសហការពីប្រជាពលរដ្ឋទាំងអស់ដើម្បីស្វែងយល់និងទទួលយកនូវការពិតមួយនេះ និងគួរឆាប់យល់ព្រមទទួលយកគោលនយោបាលសំណងដែលរាជរដ្ឋាភិបាលបានរៀបចំជូនដូចបានរៀបរាប់ខាងលើ ដើម្បីជាប្រយោជន៍ដល់ក្រុមគ្រួសាររបស់ខ្លួនផ្ទាល់។

សូមបញ្ជាក់ផងដែរថា បច្ចុប្បន្ននេះ ពុំមានប្រជាពលរដ្ឋរស់នៅក្នុងតំបន់អាងស្តុកទឹកគម្រោងវារីអគ្គិសនីសេសានក្រោម២នេះទេ ជាពិសេសនៅទីតាំងចាស់នៃភូមិស្រែគ១ ភូមិស្រែគរ២ និងភូមិក្បាលរមាស។

អាស្រ័យហេតុនេះសូមសាធារណជន ជាពិសេសអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។